ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨.០២៤.០១៦ ប្រកា.សព័ត៌មាន

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់
## ស្តីពី កិច្ចសហប្រតិបត្តិការលើការទូទាត់ឆ្លងដែនតាមយ្យូអរកូត
## និងការចែករំលែកព័ត៌មានឥណទានឆ្លងដែន
## រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ទ្វេភាគីស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមយ្យូអរកូត" ចំនួនបីដាច់ដោយឡែកពីគ្នា។ អនុស្សរណៈទី១ធ្វើឡើងជាមួយធនាគារគូកមីន (Kookmin Bank Co., Ltd.) ទី២ជាមួយស្ថាប័ន JB Financial Group Co., Ltd. និងទី៣ជាមួយធនាគារអ៊ូរី (Woori Bank)។ ក្នុងឱកាសនោះដែរ ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ត្រីភាគីជាមួយក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (កូរ៉េ) និងធនាគារ JEONBUK ស្តីពី "កិច្ចសហការចែករំលែកព័ត៌មានឥណទានឆ្លងដែន" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េផងដែរ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈទាំង៤ខាងលើ ត្រូវបានប្រារព្ធឡើងនៅក្នុងរបៀបវារៈនៃវេទិកាធុរកិច្ចកម្ពុជា-កូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចធិបតី** នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៥-១៨ ខែឧសភា ឆ្នាំ២០២៤។

អនុស្សរណៈយោគយល់ទាំងនេះ រៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងពង្រឹងការផ្លាស់ប្តូរព័ត៌មានឥណទានដែលអាចធ្វើឱ្យការផ្តល់ឥណទានកាន់តែប្រសើរ ជាពិសេស សម្រួលដល់ពលករខ្មែរចំណាកស្រុកក្នុងការបង្វែរប្រាក់ត្រឡប់មកក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជា ជំរុញវិស័យទេសចរណ៍ និងសកម្មភាពពាណិជ្ជកម្ម ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់។ កិច្ចសហប្រតិបត្តិការនេះនឹងជួយបង្កើនទំនុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្នបន្ថែមទៀតក្នុងបុព្វហេតុផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងធុរជននៃប្រទេសទាំងពីរ ព្រមទាំងគាំទ្រគោលនយោបាយដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ ស្តីពី "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"៕

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA